ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2012, 14:29
CMS/CFO: Ly Bunloung

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ៖ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០១២

**ជូនចំពោះ:** គណៈកម្មាធិការផ្នែកវិន័យនៃនាយកដ្ឋានផ្នែកតុលាការទីមួយផ្នែកឧទ្ធរណ៍ នៃតុលាការកំពូលរដ្ឋញ៉ូវយ៉ក **(Departmental Disciplinary Committee for the First Judicial Department, Appellate Division, New York State Supreme Court)**

**ពី:** ចៅក្រមនិលណុនប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** នាយកប្រតិបត្តិគណៈមេធាវីនៃរដ្ឋញ៉ូវយ៉ក
លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
ភាគីសំណុំរឿង ០០២
ផ្នែកគាំពារការការពារក្តី
គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ:** សេចក្តីបន្ថែម៖ ការបន្តការប្រព្រឹត្តិកំហុសវិជ្ជាជីវៈរបស់មេធាវី ដែលជាសមាជិករបស់គណៈមេធាវីរបស់លោក/លោកស្រី

យោងតាមសេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ (E241 និងE214/1) និងថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២ (E214/1) ដែលបានរៀបរាប់អំពីកំហុសវិជ្ជាជីវៈក្នុងទម្រង់ដដែលៗរបស់មេធាវីការពារក្តីមួយរូបឈ្មោះលោក អេនឌ្រូ អ៊ីនូហ្វ៊ី

(Andrew IANUZZI) នៅចំពោះមុខអង្គជំនុំជម្រះ ដែលមេធាវីរូបនេះ គឺជាសមាជិកមួយរូបរបស់គណៈមេធាវីនៃរដ្ឋញ៉ូវយ៉ក។

នៅពេលនេះ អង្គជំនុំជម្រះសាលាដំបូងមានបំណងជូនដំណឹងដល់លោក/លោកស្រី អំពីការបន្តប្រព្រឹត្តកំហុសវិជ្ជាជីវៈរបស់ លោក អ៊ីនូហ្ស៊ី នៅក្នុងអំឡុងពេលក្រោយពីការជូនដំណឹងនោះ។ អង្គជំនុំជម្រះសាលាដំបូងនឹងសូមថ្លែងអំណរគុណ ប្រសិនបើមានការពិចារណាទៅលើករណីកំហុសវិជ្ជាជីវៈលើកនេះ បន្ថែមទៅលើករណីអង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងលិខិតយោងចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ និងលិខិតយោងចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១២។

នៅក្នុងអំឡុងពេលដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ លោក អ៊ីនូហ្ស៊ី បានធ្វើការអធិប្បាយដូចខាងក្រោម (ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ២៧-២៨ (សម្រង់))[1]។

> លោក អ៊ីនូហ្ស៊ី៖
> សូមអរគុណលោកប្រធាន។ ខ្ញុំបានព្យាយាមដោយទទួលបាននូវការណែនាំ គឺថាព្យាយាមគោរពទៅតាមការណែនាំនេះ ប៉ុន្តែនេះគឺជាលើកទី១ ហើយដែលខ្ញុំបានឮអំពីលក្ខខណ្ឌបែបនេះទាក់ទងនឹងការដាក់ឯកសារ។ គេបានជម្រាបយើងថា យើងអាចដាក់ឯកសារណាក៏បាន ដែលយើងគិតថាវាពាក់ព័ន្ធទៅនឹងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ។ នៅពេលដែលយើងទទួលបានការជម្រាបនៅម៉ោងដប់មួយ គឺថាមុន ២នាទីមុនខ្ញុំចាប់ផ្តើមធ្វើបទបង្ហាញនេះ គឺថាខ្ញុំមិនអាចដាក់ឯកសារពីរដែលខ្ញុំបាននិយាយនេះ។ ខ្ញុំគិតថា វាជាការគួរឱ្យចាប់អារម្មណ៍ជាទីបំផុតទៅលើការណែនាំបែបនេះ។
> តើទទួលបាននូវការសម្រេចហ្នឹងដោយសារតែផ្អែកទៅលើមូលដ្ឋានអ្វីដែរឬទេ? នេះគឺជាអ្វីដែលខ្ញុំ --
>
> ប្រធានអង្គជំនុំជម្រះ៖
> សូមអញ្ជើញ! យើងបានជម្រាបអំមិញហើយថា យើងបាននិយាយរួចហើយអំពីហេតុផលដែលសម្រេចថា សុំឱ្យលោកបង្អង់ទុកនូវការបង្ហាញឯកសារទាំងពីរនេះសិន ដោយសារមូលហេតុអង្គជំនុំជម្រះបានជម្រាបជូនរួចហើយ។ យើងមិននិយាយសាឡើងវិញដដែលទេ។ ហើយឱកាស

[1] បន្ថែមលើអនុស្សរណៈនេះ គឺទំព័រពាក់ព័ន្ធទាំងមូល ដែលត្រូវបានដកស្រង់នៅក្នុងអនុស្សរណៈនេះ។

នៅក្នុងការដាក់បង្ហាញឯកសារនេះ អង្គជំនុំជម្រះនឹងផ្តល់ជូនភាគីនៅពេលក្រោយ។ ពេលសមស្របណាមួយ ជាពិសេសគឺកាលវិភាគសម្រាប់ការស្តាប់សក្ខីកម្មអ្នកជំនាញ ដែលអង្គជំនុំជម្រះនឹងសម្រេចផ្តល់ សម្រេចកោះអញ្ជើញគាត់ឱ្យមកផ្តល់សក្ខីកម្ម ដែលយើងបានកំណត់រួចហើយ។ ករណី ហ្វីលីព ស្សូត ដោយឡែក ស្ទីវិន ហេដឌ័រ គឺយើងមិនទាន់បានសម្រេចឱ្យបានច្បាស់លាស់ថា អញ្ជើញគាត់មកផ្តល់សក្ខីកម្ម ឬអត់នោះទេ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនដល់ភាគី ដើម្បីដាក់នូវឯកសារដែលពាក់ព័ន្ធជាមួយនឹងអ្នកជំនាញស្នាដៃអ្នកជំនាញទាំងអស់នេះ នៅពេលសមស្របណាមួយ។

មុនពេលសម្រាកបរិភោគអាហារថ្ងៃត្រង់ នៅថ្ងៃដំណើរការនីតិវិធីដដែលនេះ លោក អ៊ីនូហ្សី បានបន្តរឿងនេះទៀត (ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៥៧-៥៨)៖

ប្រធានអង្គជំនុំជម្រះ៖
សូមអញ្ជើញ! លោកចង់មានបញ្ហាអីទៀតហើយ?

លោក អ៊ីនូហ្សី៖
សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោស ខ្ញុំចង់លើកឡើងនូវចំណុចមួយដែលថាសហការីរបស់ខ្ញុំគឺលោក វែកគែន បានលើកឡើងនូវបញ្ហាថ្មីមួយ ហើយបញ្ហាថ្មីមួយនេះ គឺថាតើភាគីនានាអាចបញ្ចេញមតិបានដែរឬទេ? គឺថាខ្ញុំគាំទ្រជាមួយនឹងអ្វីដែលលើកឡើងនេះ គឺថានៅពេលព្រឹកមិញ គឺថាមានការធ្វើបែបនេះមែន គឺអត់មានការជម្រាបទៅដល់ភាគីនានា។ គឺថាពួកយើងនៅខាងការពារក្តីហ្នឹង អាចធ្វើការជំទាស់ អាចធ្វើមតិយោបល់សំខាន់ៗ អាចឆ្លើយតប អាចធ្វើអ្វីមួយដើម្បីបញ្ជាក់ ដើម្បីជាការឆ្លើយតបទៅនឹងអ្វីដែលបានលើកឡើង។ អ្វីដែលជម្រាបមកយើងបាន គឺថាឯកសារ គឺការបង្ហាញពីឯកសារ។ ហើយអ្វីដែលខាងមេធាវីខៀវ សំផន ប្រើប្រាស់ថាសន្និសីទកាសែតហ្នឹង គឺសមរម្យមែនទែន គឺថាដោយសារតែមិនមានការជំទាស់ ដោយមានការពិភាក្សាទៅតាមអ្វីដែលយើងបានជម្រាប។ ដូច្នេះ លោកប្រធានកាលពីព្រឹកនេះ បានជម្រាបខ្ញុំ ខាងមកយើងថា នេះគឺជាការជំនុំជម្រះមួយដែល -- នេះដូច្នេះខ្ញុំគិតថាអ្វីដែលលោក --

ដើម្បីឆ្លើយតបទៅនឹងការអធិប្បាយទាំងនេះ និងនៅពេលបន្តឡើងវិញនូវដំណើរការនីតិវិធីនាថ្ងៃដដែលនោះ លោកចៅក្រម ឡាវែន៍ តាងនាមឲ្យប្រធានអង្គជំនុំជម្រះសាលាដំបូង បានធ្វើសេចក្តីសម្រេចដូចតទៅនេះ (ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២ ទំព័រ ៥១-៥២)៖

បាទ ទាក់ទងនឹងការសម្រេចលើលោកមេធាវី អ៊ីន្ទូហ្សី សូមលោកមេធាវីក្រោកឈរ!

កាលពីសវនាការកាលពីព្រឹកមិញនោះ មេធាវី អ៊ីន្ទូហ្សី ដែលជាមេធាវីអន្តរជាតិរបស់ក្រុមការពារក្តីលោក នួន ជា បាន -- ជាថ្មីម្តងទៀត ធ្វើការអត្ថាធិប្បាយសំដៅបដិសេធ និងទិតៀនដល់សេចក្តីសម្រេចដែលអង្គជំនុំជម្រះបានចេញរួចហើយក្នុងនាមតុលាការទាំងមូល ទាក់ទងនឹងការដឹកនាំសវនាការ។ ហើយការធ្វើអត្ថាធិប្បាយនេះនោះ គឺថាបានធ្វើឡើងនៅក្នុងខណៈដែលគាត់ហ្នឹងត្រូវបាន គាត់ត្រូវបានព្រមានជាច្រើនដងហើយថា អាកប្បកិរិយាបែបនេះមិនស្របទេ ហើយមិនត្រូវបន្តធ្វើទៀតទេ។ លើសពីនេះទៅទៀត ការធ្វើអត្ថាធិប្បាយនេះ គាត់ធ្វើអត្ថាធិប្បាយនៅពេលដែលគាត់និយាយទៅកាន់លោកប្រធាន ថាលោកប្រធាននេះជាចៅក្រមដ៏គួរឲ្យកត់សម្គាល់។ ហើយរបៀបដែលនិយាយពាក្យពេចន៍ទាំងអស់នេះ ហើយនឹងសូរសៀងនិយាយទាំងអស់នេះ គឺថាវាបង្ហាញថាមានលក្ខណៈមិនត្រឹមត្រូវ មិនគួរសម ឬមិនគោរពទេ វាថែមទាំងជាការជេរប្រមាថដល់ចៅក្រមប្រធាន ហើយនឹងអង្គចៅក្រមទាំងមូលទៀតផង។

អាស្រ័យហេតុដូច្នេះ អាកប្បកិរិយាទាំងអស់នេះ មិនសមស្រប ហើយនឹងមិនអាចទទួលយកបានអង្គជំនុំជម្រះ សូមព្រមានដល់លោកមេធាវី អ៊ីន្ទូហ្សី ថា ដោយយោងទៅតាមវិធាន៣៨ នៃវិធានផ្ទៃក្នុងថាវាគឺជាការមិន -- អាកប្បកិរិយាមិនល្អ មិនសមរម្យ ហើយនឹងអាចបង្កើតឲ្យមានការដាក់ទណ្ឌកម្មមួយទៅលើគាត់ រហូតដល់ការដែលមិនអនុញ្ញាតឲ្យគាត់ចូលរួមក្នុងសវនាការទៀតផង។

ប្រសិនបើលោក/លោកស្រី មានសំណួរចង់សួរបន្ថែម ឬចង់បានព័ត៌មានបន្ថែមពីអង្គជំនុំជម្រះសាលាដំបូង សូមលោក/លោកស្រីមេត្តាទំនាក់ទំនងជាមួយ៖

**Susan Lamb** (lamb@un.org)
មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
ប្រអប់សំបុត្រលេខ ៧១
ភ្នំពេញ, ប្រទេសកម្ពុជា

ឯកសារភ្ជាប់មកជាមួយ